# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តព្រៃវែង**

សំណុំរឿងព្រហ្មទណ្ឌលេខ: ៤២២

ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦

សាលក្រមលេខ: ២៣/០៨ (ច)

ថ្ងៃព្រហស្បតិ៍ ១០រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តព្រៃវែង

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តព្រៃវែង នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ វេលាម៉ោងប្រាំបី និង សូន្យនាទីព្រឹក ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤២២ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦ ដោយមានសមាសភាពដូចតទៅ ៖

## ចៅក្រមជំនុំជម្រះ

-លោកស្រី [redacted] ជាចៅក្រមសាលាដំបូងខេត្តព្រៃវែង

## តំណាងអយ្យការ

-លោក [redacted] ជាព្រះរាជអាជ្ញារង

## ក្រឡាបញ្ជីសវនាការ

-លោកស្រី [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តព្រៃវែង

ជនជាប់ចោទ ៖

១.ឈ្មោះ [redacted] ភេទប្រុស អាយុ៤៧ឆ្នាំ ជនជាតិខ្មែរ មុខរបរ:.... កើតនៅភូមិ [redacted] ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នភូមិកា [redacted] ខេត្តព្រៃវែង ប្រពន្ធឈ្មោះ [redacted] សុឃា (រ) មានកូនចំនួន០៤នាក់ ឪពុកឈ្មោះ [redacted] ខន (រ) ម្តាយឈ្មោះ [redacted] ម៉ន "រ" ជានីតិជន ទោសពីមុន.គ្មាន *ក្រៅឃុំ* ។

២.ឈ្មោះ [redacted] **សុឃា** ភេទស្រី អាយុ៤៥ឆ្នាំ ជនជាតិខ្មែរ មុខរបរ: កសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តព្រៃវែង ប្តីឈ្មោះ [redacted] ខឿន (រ) មានកូនចំនួន០៤នាក់ ឪពុកឈ្មោះ [redacted] ចេង (ស) ម្តាយឈ្មោះ [redacted] ណាប "ស" ជានីតិជន ទោសពីមុន.គ្មាន *ក្រៅឃុំ* ។

ត្រូវបានចោទប្រកាន់ពីបទ: **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិកាឡីខាងជើង ឃុំស្លី(ក) ស្រុកបាភ្នំ ខេត្តព្រៃវែង កាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វ៉ាង ភេទប្រុស អាយុ៤៥ឆ្នាំ ជនជាតិខ្មែរ មុខរបរៈ កសិករ មានទីលំនៅបច្ចុប្បន្នភូមិមហាស្នួន ឃុំស្វាយយា ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង។

មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ លោកស្រី [redacted] មានទីតាំងស្ថិតនៅអគាររលេខ.១១៥៩ ផ្លូវលេខ.២ ភូមិព្រែកតានូ សង្កាត់ចាក់អង្រែ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ លោក [redacted] មានទីតាំងស្ថិតនៅអគាររលេខ.១១៥៩ ផ្លូវលេខ.២ ភូមិព្រែកតានូ សង្កាត់ចាក់អង្រែ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

## អង្គហេតុនៃបណ្តឹងចោទប្រកាន់

កាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៦ ឈ្មោះ [redacted] សុឃា បានយកចបទៅកាប់ដីទប់ទឹកនៅតាមផ្លូវលំចេញពីផ្ទះនៅមុខផ្ទះរបស់ឈ្មោះ [redacted] វណ្ណា (ហៅ ចក់) ពេលកំពុងតែកាប់ឈ្មោះ [redacted] វណ្ណា បានមកដល់ក៏ប្រាប់ថាឱ្យកាយបង្ហូរទឹកវិញតែឈ្មោះ [redacted] សុឃា បានតបថាឯងទៅផ្ទះឱ្យឆាប់តែឈ្មោះ [redacted] វណ្ណា មិនព្រមទៅក៏បានប្រកែកគ្នាមិនឱ្យឈ្មោះ [redacted] សុឃា ទប់ទឹក ក៏ត្រូវបានប្រតាយប្រតប់គ្នាឈ្មោះ [redacted] សុឃា បានស្រែកហៅប្តីខ្លួនឈ្មោះ [redacted] ខឿន ដែលនៅឯផ្ទះមកជួយពេលឈ្មោះ [redacted] ខឿន មកដល់ក៏បានវាយទៅលើឈ្មោះ [redacted] វណ្ណា មួយដៃត្រូវចំមាត់បណ្តាយឱ្យរបួសដាច់បបូរមាត់ពេលនោះ ដែលឈ្មោះ សាត (ម្តាយក្មេក) របស់ឈ្មោះ [redacted] វណ្ណា បានឮនិងឃើញពីសកម្មភាពនេះក៏ បានចេញមកជួយឃាត់ក៏ត្រូវបានឈ្មោះ [redacted] ខឿន ទាត់ត្រូវមួយជើងផងដែរ ។

**-បានឃើញ** ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៨៤៧ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រៃវែង ។

**-បានឃើញ** កំណត់ហេតុជំនុំជម្រះរបស់សាលាដំបូងខេត្តព្រៃវែង ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **ខឿន** បានឆ្លើយថាៈ នៅថ្ងៃកើតហេតុពេលខ្លួនកំពុងតែដាក់ចំបើងឱ្យគោ ស្រាប់តែបានឮសំឡេងប្រពន្ធរបស់ខ្លួនស្រែកថាៈ ជួយផងអាចក់ចាប់ខ្លួនហើយ ពេលខ្លួនទៅមើលឃើញឈ្មោះ វណ្ណា (ចក់) មានឈាមទៅហើយ គឺគាត់បានប្រតាយប្រតបជាមួយប្រពន្ធរបស់ខ្លួន ។ ពេលនោះខ្លួនឃើញឈ្មោះ វណ្ណា បានយកព្រនង់ដេញវាយប្រពន្ធរបស់ខ្លួន ខ្លួនក៏បានទៅដណ្តើមយកព្រនង់នោះចេញ តែខ្លួនមិនបានវាយទៅលើឈ្មោះ វណ្ណា ទេ ។ នៅពេលកើតហេតុយាយសាតត្រូវជាម្តាយក្មេករបស់ឈ្មោះ វណ្ណា ក៏បានមកជួយឃាត់ដែរ ។

-ជនជាប់ចោទឈ្មោះ [redacted] សុឃា បានឆ្លើយថាៈ ខ្លួនត្រូវជាប្រពន្ធរបស់ឈ្មោះ [redacted] ខឿន និងត្រូវជាមីងថ្លៃរបស់ឈ្មោះ វណ្ណា ។ ប្រពន្ធរបស់ឈ្មោះ វណ្ណា បានស្លាប់ហើយ ។ ខ្លួន និងឈ្មោះ វណ្ណា ធ្លាប់ឈ្លោះគ្នាតាំងពីឆ្នាំ២០១៤ មកម្ល៉េះ ។ នៅថ្ងៃកើតហេតុ ក្រោយពេលភ្លៀងធ្លាក់ ខ្លួនបានកាយពង្រាបដីផ្លូវថ្នល់កុំអោយខូង ពេលកាយទៅដល់មុខផ្ទះឈ្មោះ វណ្ណា ស្រាប់តែឈ្មោះ វណ្ណា ស្រែកថាៈ កាយអោយអញអោយដូចដើមវិញ ពេលនោះខ្លួនតបវិញថាៈ ចេញទៅអញមិននិយាយជាមួយមនុស្សស្រវឹងទេ ស្រាប់តែឈ្មោះ វណ្ណា បានស្ទុះមកអោបខ្លួន ខ្លួនក៏បានច្រានឈ្មោះ វណ្ណា ចេញ ហើយបានស្រែកហៅប្តីអោយជួយ ពេលនោះខ្លួនបានច្រានឈ្មោះ វណ្ណា ដួលទៅលើរបង ។ ខ្លួនមិនបានវាយទៅលើឈ្មោះ វណ្ណា ទេ។ ពេលខ្លួនច្រានឈ្មោះ វណ្ណា មិនដឹងថាប៉ះអ្វីទេ ។ ពេលប្តីខ្លួនមកដល់គាត់បានជួយចាប់ឈ្មោះ វណ្ណា ចេញ ។

-ជនរងគ្រោះឈ្មោះ [redacted] **វណ្ណា** បានឆ្លើយថាៈ នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល១៧និង៣០នាទី ខ្លួនបានដើរចេញពីផ្ទះឈ្មោះ [redacted] សាមាន ភេទស្រី អាយុ៤៨ឆ្នាំ នៅភូមិជាមួយខ្លួន ដើម្បីទៅផ្ទះរបស់ខ្លួន ពេលទៅដល់មាត់របងផ្ទះរបស់ខ្លួន បានឃើញឈ្មោះ [redacted] សុឃា ភេទស្រី អាយុ៤៥ឆ្នាំ កំពុងយកចបមកទប់ទឹក នៅក្បែរមាត់របងផ្ទះ



Scanned with CamScanner

របស់ខ្លួន ពេលនោះរូបខ្លួនបានឃាត់ឈ្មោះ [redacted] សុឃា មិនឱ្យទប់ទឹកព្រោះខ្លាចលិចស្រូវរលួយអស់ ស្រាប់តែឈ្មោះ [redacted] សុឃា បានវាយរូបខ្លួនមួយដងចប ហើយបានស្រែកហៅប្ដីរបស់គាត់ឈ្មោះ [redacted] ខៀន ពេលនោះប្ដីរបស់គាត់ឈ្មោះ [redacted] ខៀន បានមកដល់ក៏សន្ទុះមកវាយរូបខ្លួនចំមុខជាច្រើនដៃបណ្ដាលឱ្យរូបខ្លួនដួលសន្លប់នៅនឹងដី ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted]វ៉ាង បានឆ្លើយថា: នៅពេលកើតហេតុខ្លួនមិនបានឃើញទេ គឺប្អូនថ្លៃទូរស័ព្ទប្រាប់ថាម្ដាយខ្លួននិងប្អូនរបស់ខ្លួនទៅមន្ទីរពេទ្យហើយ ព្រោះត្រូវគេវាយ ខ្លួនក៏បានទៅដល់មន្ទីរពេទ្យបានឃើញឈ្មោះ [redacted] វណ្ណា មានរបួសមាត់ខាងលើវាងធំបន្តិច មិនមានបាក់ធ្មេញទេ ឃើញមានរបួសក ក្រៅពីនេះមិនឃើញទេ ។

-សាក្សីឈ្មោះ [redacted]អ៊ន់ បានឆ្លើយថា: ខ្លួនត្រូវជាប្អូនបង្កើតរបស់ឈ្មោះ [redacted]សាត ។ ពេលកើតហេតុខ្លួនមិនបានដឹងរឿងអ្វីឡើយ ។ លុះក្រោយពេលកើតហេតុទើបមានអ្នកជិតខាងប្រាប់ខ្លួន ខ្លួនក៏បានទៅសួរយាយសាត គាត់ថា អ្អែងមើល មានរឿងឈ្លោះគ្នា អញរុញវាចូលផ្ទះបិទទ្វារហើយ វារុលកាន់ព្រនង់ចូលក្បាលជាប់របងឬស្សី វាមិនស្គាល់ងាប់សោះ តែមិនឮគាត់និយាយថា ឈ្មោះ ចក់ ត្រូវគេវាយឡើយ ។ ឈ្មោះ [redacted]សាត បានប្រាប់ខ្លួនថា គាត់បានធ្លាក់ពីលើជណ្ដើរដល់ក្រោមឈើមួយចំហៀងខ្លួន ។

-សាក្សីឈ្មោះ [redacted]**សាមាន** បានឆ្លើយថា: ខ្លួនត្រូវជាក្មួយរបស់ឈ្មោះ សុឃា និងត្រូវជាកូនរបស់ឈ្មោះ [redacted] សាត ។ ខ្លួនជាសាក្សីខាងជនរងគ្រោះ ។ នៅថ្ងៃកើតហេតុខ្លួនមិនបានឃើញទេ គ្រាន់តែឃើញម្ដាយដឹកដៃជនរងគ្រោះទៅមន្ទីរពេទ្យ ។ ឈ្មោះ [redacted]សាត បានប្រាប់ខ្លួនថា របួសរបស់គាត់នៅចំម្ដៅនោះ គឺឈ្មោះ [redacted]ខៀន ជាអ្នកធាក់ ហើយរឿងដែលគាត់ធ្លាក់ពីលើផ្ទះនោះគឺ០២ឆ្នាំហើយ ។ ខ្លួនមិនបានដឹងថាឈ្មោះ [redacted] សាត ត្រូវរបួសត្រង់ណាទេ ។

## មេធាវីការពារសិទ្ធឱ្យជនជាប់ចោទបានសន្និដ្ឋានថា

ផ្អែកតាមអង្គហេតុឃើញថា កូនក្ដីខ្លួនគ្មានចេតនាប្រព្រឹត្តអំពើហិង្សាទៅលើឈ្មោះ [redacted] វណ្ណា ឡើយ ដោយសារតែឈ្មោះ វណ្ណា ស្រវឹងស្រា គឺគ្រាន់តែការពារខ្លួនប៉ុណ្ណោះ ។ ដើមបណ្ដឹងសរសេរក្នុងពាក្យបណ្ដឹង ដូចជាច្បាស់ ប៉ុន្តែពេលសវនាការមិនច្បាស់ ។ ឆ្លងតាមការដេញដោល កំណត់ហេតុពិនិត្យស្នាមរបួស ភស្តុតាង ជនជាប់ចោទថា ការប្រតាយប្រតបព្រោះការពារខ្លួន ដោយសារជនរងគ្រោះមកអោបខ្លួន ។ របួសនេះតើកើតចេញពីជនជាប់ចោទ ឬស្ថានភាពកាលៈទេសៈផ្សេងទៀត បើគាត់ជាស្រី ? ហើយជនរងគ្រោះបាននិយាយថា ជនជាប់ចោទបានយកដងចបវាយខ្លួន ដូច្នេះត្រូវមានស្នាមរបួសជាំ តែក្នុងកំណត់ហេតុពិនិត្យស្នាមរបួសគ្មានទេ ។ បើតាមការអះអាងរបស់ជនជាប់ចោទ ថាខ្លួនបានរុញជនរងគ្រោះដួលទៅលើរបង ដូច្នេះក៏ត្រូវបានមុតបណ្ដាលឱ្យរលាត់ក ដូចមានក្នុងកំណត់ហេតុ។

## សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

ឆ្លងតាមការដេញដោលរបស់ជនរងគ្រោះ និងជនជាប់ចោទឃើញថា ពិតជាមានទំនាស់ជាមួយគ្នាមែន ហើយឈានដល់ការប្រតាយប្រតបគ្នារហូតដល់មានរបួសស្នាម ដូច្នេះតំណាងអយ្យការនៅតែរក្សាការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល ។

## សម្ដីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទសុំឱ្យតុលាការបន្ធូរបន្ថយទោស ព្រោះខ្លួនដឹងកំហុសហើយ។

-ក្រោយពីបានស្ដាប់ចម្លើយដើមបណ្ដឹង និងសាក្សី

-ក្រោយពីបានស្ដាប់ ចម្លើយរបស់ជនជាប់ចោទ និងសម្ដីចុងក្រោយ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងនានាក្នុងសំណុំរឿង



Scanned with CamScanner

-ក្រោយពីបានពិនិត្យ និងពិចារណាលើសំណុំរឿងនេះចប់សព្វគ្រប់។

## សំអាងហេតុ

១. តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌជំនុំជម្រះពីបទៈ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិកាឡីខាងជើង ឃុំស្តី(ក) ស្រុកបាភ្នំ ខេត្តព្រៃវែង កាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។ ដែលមានជនជាប់ចោទឈ្មោះ [redacted] ខឿន ភេទប្រុស អាយុ៤៧ឆ្នាំ និងឈ្មោះ [redacted] សុឃា ភេទស្រី អាយុ៤៥ឆ្នាំ តាមដីកាដំណោះស្រាយលេខ.៨៨៧ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រៃវែង ។

២. ផ្អែកតាមចម្លើយនាពេលសវនាការរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយរបស់ជនរងគ្រោះ ព្រមទាំងភស្តុតាងផ្សេងៗទៀត ក៏ដូចជាសាក្សីបានបង្ហាញថា ជនជាប់ចោទទាំងពីរនាក់ខាងលើពិតជាបានវាយទៅលើជនរងគ្រោះប្រាកដមែន។

៣. ចំពោះចម្លើយបដិសេធរបស់ជនជាប់ចោទឈ្មោះ [redacted] ខឿន និងឈ្មោះ [redacted] សុឃា ថាខ្លួនមិនបានវាយទៅលើជនរងគ្រោះនោះ តុលាការយល់ឃើញថា គ្រាន់តែជាចម្លើយឆ្លើយដោះសារដើម្បីឱ្យពួកខ្លួនបានរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌប៉ុណ្ណោះ ។

៤. អំពើរបស់ជនជាប់ចោទទាំងពីរនាក់ខាងលើដែលវាយទៅលើជនរងគ្រោះ គឺមានធាតុផ្សំនៃបទល្មើស **ហិង្សាដោយចេតនា** តាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

៥. ជនជាប់ចោទឈ្មោះ [redacted] ខឿន និងឈ្មោះ យី សុឃា គឺជានីតិជន មានសតិសម្បជញ្ញៈ និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌនូវទង្វើរបស់ពួកខ្លួន ។

៦. សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ នាពេលសវនាការដែលបានចោទប្រកាន់លើឈ្មោះ [redacted] ខឿន និងឈ្មោះ [redacted] សុឃា ពីបទ **ហិង្សាដោយចេតនា** ហើយបានតម្កល់បទចោទទុកជាបានការដដែល តុលាការនឹងយកជាមូលដ្ឋានក្នុងការពិចារណាសម្រេច ។

៧. សេចក្តីសន្និដ្ឋានរបស់មេធាវី នាពេលសវនាការ តុលាការនឹងយកជាមូលដ្ឋានក្នុងការពិចារណា និងសម្រេច ។

៨. មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ខឿន ភេទប្រុស អាយុ៤៧ឆ្នាំ និងឈ្មោះ [redacted] សុឃា ភេទស្រី អាយុ៤៥ឆ្នាំ ពីបទ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិកាឡីខាងជើង ឃុំស្តី(ក) ស្រុកបាភ្នំ ខេត្តព្រៃវែង កាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៦ ។

៩. អំពើដែលជនជាប់ចោទឈ្មោះ [redacted] ខឿន និងឈ្មោះ [redacted] សុឃា បានប្រព្រឹត្ត គឺធ្វើឱ្យប៉ះពាល់ទៅដល់សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ និងប៉ះពាល់ដល់រូបរាងកាយបុគ្គល ដូច្នេះទណ្ឌកម្មដែលត្រូវអនុវត្តលើជនជាប់ចោទ តុលាការនឹងពិនិត្យពិចារណា ។

១០. នៅពេលសវនាការ ដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើការទាមទារសំណងរដ្ឋប្បវេណីជាទឹកប្រាក់ចំនួន ២.០០០$ (ពីរពាន់ដុល្លារអាមេរិក) តុលាការនឹងពិចារណាតាមភាពសមរម្យ ។

## ហេតុដូច្នេះសម្រេច

១. ផ្តន្ទាទោសឈ្មោះ [redacted] ខឿន ភេទប្រុស អាយុ៤៧ឆ្នាំ និងឈ្មោះ [redacted] សុឃា ភេទស្រី អាយុ៤៥ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ) ឆ្នាំ តែទោសនេះត្រូវព្យួរទម្ងន់ ពីបទ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិកាឡីខាង

ដើង ឃុំស្ពឺ(ក) ស្រុកបាភ្នំ ខេត្តព្រៃវែង កាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

**២.** បង្គាប់ឱ្យឈ្មោះ [redacted] **ខឿន** ភេទប្រុស អាយុ៤៧ឆ្នាំ និងឈ្មោះ [redacted] សុឃា ភេទស្រី អាយុ៤៥ឆ្នាំ (មានសាវតាជាតិដូចខាងលើ) សងសំណងទៅដើមបណ្តឹងរដ្ឋប្បវេណីជាទឹកប្រាក់ចំនួន ២.០០០.០០០៛ (ពីរលានរៀល) ។ ការទាមទារលើសពីនេះត្រូវច្រានចោល ។

សាលក្រមនេះ ជំនុំជម្រះ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។

**ក្រឡាបញ្ជី** | **ចៅក្រមជំនុំជម្រះ**

[redacted] | [redacted]